ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរអគ្គិសនីកម្ពុជា

លេខ ២៩៧ សាក.១៦ អអក

ភ្នំពេញ, ថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ២០១៦

# សេចក្តីជូនដំណឹងរបស់អាជ្ញាធរអគ្គិសនីកម្ពុជា ស្តីពីការបញ្ចុះអត្រាថ្លៃផ្គត់ផ្គង់អគ្គិសនីនៅស្រុកស្ទោង និងនៅផ្នែកខ្លះស្រុកប្រាសាទបល្ល័ង្គ ខេត្តកំពង់ធំ ក្នុងតំបន់ផ្គត់ផ្គង់អគ្គិសនីរបស់សេវាករឈ្មោះ អ៊ុង ហុកស៊ុន និងសេវាករឈ្មោះ ឃុន ណៃហៀក

យោង៖
- ការសម្រេចឯកភាពពីអគ្គិសនីកម្ពុជា បន្ថយអត្រាថ្លៃលក់អគ្គិសនីដុំ ចំនួន ២០០ រៀល ក្នុង ១ គីឡូវ៉ាត់ម៉ោង ឲ្យខ្សែបញ្ជូនរង លក់ឲ្យសេវាករនៅស្រុកស្ទោង ខេត្តកំពង់ធំ
- របាយការណ៍នៃកិច្ចប្រជុំនៅវត្តព្រះនាង ឃុំកំពង់ចិនខាងត្បូង ស្រុកស្ទោង ខេត្តកំពង់ធំ កាលពីថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៦

អាជ្ញាធរអគ្គិសនីកម្ពុជា សូមជម្រាបជូនសាធារណជន**អ្នកប្រើប្រាស់អគ្គិសនីក្នុងតំបន់ផ្គត់ផ្គង់អគ្គិសនី** របស់សេវាករឈ្មោះ អ៊ុង ហុកស៊ុន និងសេវាករឈ្មោះ ឃុន ណៃហៀក ធ្វើសេវាកម្មផ្គត់ផ្គង់អគ្គិសនីនៅស្រុកស្ទោង និងផ្នែកខ្លះស្រុកប្រាសាទបល្ល័ង្គ ខេត្តកំពង់ធំ មេត្តាជ្រាបថា កន្លងមក អាជ្ញាធរអគ្គិសនីកម្ពុជាបានសម្រេចអនុញ្ញាតឲ្យ **ក្រុមហ៊ុន ប៊ី វី ស៊ី ផៅវ័រ ឌីវែឡុបមិន** ធ្វើការវិនិយោគសាងសង់ខ្សែពង្រីកបណ្តាញបញ្ជូនរងបន្តពីក្រុងស្ទឹងសែន និងស្រុកកំពង់ស្វាយ រហូតដល់ស្រុកស្ទោង និងផ្នែកខ្លះស្រុកប្រាសាទបល្ល័ង្គ ខេត្តកំពង់ធំ ដើម្បីបញ្ជូនអគ្គិសនីចេញពីអនុស្ថានីយក្រុងកំពង់ចាម មានចម្ងាយឆ្ងាយ ដើម្បីបន្ទុបន្ថយអត្រាថ្លៃលក់ឲ្យថយចុះបន្តិចម្តងៗ សម្រួលដល់ប្រជាពលរដ្ឋអ្នកប្រើប្រាស់។ បន្ទាប់ពីទទួលបានការសម្រេចឯកភាពពីអគ្គិសនីកម្ពុជា បន្ថយអត្រាថ្លៃលក់អគ្គិសនីដុំចំនួន ២០០ រៀល ក្នុង១ គីឡូវ៉ាត់ម៉ោង ឲ្យខ្សែបញ្ជូនរងរបស់ក្រុមហ៊ុន ប៊ី.វី.ស៊ី ផៅវ័រ ឌីវែឡុបមិន ដើម្បីបន្ថយថ្លៃលក់អគ្គិសនីដុំឲ្យសេវាករទាំង ២ នៅស្រុកស្ទោង និងផ្នែកខ្លះស្រុកប្រាសាទបល្ល័ង្គ ខេត្តកំពង់ធំ និងយោងតាមស្មារតីកិច្ចប្រជុំនៅវត្តព្រះនាង ឃុំកំពង់ចិនខាងត្បូង ស្រុកស្ទោង ខេត្តកំពង់ធំ កាលពីថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៦ អាជ្ញាធរអគ្គិសនីកម្ពុជាសម្រេចបញ្ចុះអត្រាថ្លៃអគ្គិសនី នៅតំបន់ផ្គត់ផ្គង់អគ្គិសនីរបស់សេវាករឈ្មោះ អ៊ុង ហុកស៊ុន និងសេវាករឈ្មោះ ឃុន ណៃហៀក **ចុះពីអត្រាថ្លៃលក់ ១,៥០០ រៀល/គីឡូវ៉ាត់ម៉ោង មក ១,៣០០ រៀល/គីឡូវ៉ាត់ម៉ោង អនុវត្តគិតពីពេលចេញវិក្កយបត្រថ្លៃអគ្គិសនីប្រើប្រាស់ ចាប់ពីចុងខែមិថុនា ឆ្នាំ២០១៦ តទៅ** រហូតមានប្រភពថ្មីពីខេត្តសៀមរាប នៅឆ្នាំ២០១៧ អាជ្ញាធរអគ្គិសនីកម្ពុជានឹងធ្វើការ

ពិនិត្យ និងកំណត់អត្រាថ្លៃលក់អគ្គិសនីឡើងវិញ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល និង ស្របតាមការកំណត់របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ។

អាស្រ័យហេតុនេះ សូមអ្នកប្រើប្រាស់អគ្គិសនី អាជ្ញាធរមូលដ្ឋាន និងអ្នកពាក់ព័ន្ធទាំងអស់ ក្នុង តំបន់ផ្គត់ផ្គង់អគ្គិសនីរបស់សេវាករឈ្មោះ អ៊ុង ហុកស៊ីន និងសេវាករឈ្មោះ យុន ណៃហៀក មេត្តាជ្រាបជា ពត៌មាន និងអនុវត្តឲ្យមានប្រសិទ្ធភាព។

**អាជ្ញាធរអគ្គិសនីកម្ពុជា**
**ប្រធាន**

**បណ្ឌិត.ឆី នរិន្ទ**

ចម្លងជូន
- ក្រសួងរ៉ែ និងថាមពល
- សាលាខេត្តកំពង់ធំ
- មន្ទីររ៉ែ និងថាមពលខេត្តកំពង់ធំ
- សាលាស្រុកស្ទោង
- សាលាឃុំពាក់ព័ន្ធ

"ដើម្បីជូនជ្រាប"

- ក្រុមហ៊ុន ប៊ី.វី.ស៊ី ផៅវ័រ ឌីវែឡុបមិន
- សេវាករ អ៊ុង ហុកស៊ីន
- សេវាករ យុន ណៃហៀក

"ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"

- ឯកសារ-កាលប្បវត្តិ